# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ រយៈពេល ៣ ឆ្នាំ (២០១៧ - ២០១៩)

ឈ្មោះសហគមន៍ : អភិវឌ្ឍន៍ស្ពានគ្រង

ឃុំ : ចំណាក្រោម

ស្រុក : ស្ទោង

ខេត្ត : កំពង់ធំ

## មាតិកា


**១. ស្ថានភាពទូទៅ** .......... 4

**២.. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** .......... 5

ក- ប្រជាពលរដ្ឋ .......... 5

ខ-មុខរបរ .......... 5

**៣. កន្លែងនេសាទសហគមន៍ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគន៍** .......... 6

ក.ទីតាំង .......... 6

ខ. ដែននេសាទ .......... 6

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស .......... 7

ឃ. ធនធានជលផល .......... 7

**៤. ការធ្វើនេសាទ** .......... 8

ក. អ្នកនេសាទ .......... 8

ខ. ឧបករណ៍នេសាទ .......... 8

គ. ប៉ាន់ប្រម៉ាណផលចាប់ផលនេសាទប្រចាំឆ្នាំ .......... 10

**៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** .......... 10

ក. ទស្សនៈវិស័យ .......... 10

ខ. គោលបំណង .......... 10

គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ .......... 11

គ១.-ផែនការប្រើប្រាស់ឧបករណ៍នេសាទ .......... 11

គ.២ ផែនការកែលម្អដែននេសាទ .......... 12

គ.៣ ផែនការកែលំអរ និងរៀបចំកន្លែងអភិរក្ស .......... 13

គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក .......... 13

គ. ៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម .......... 14

គ. ៦ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ .......... 14

គ. ៧ ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព .......... 14

គ. ៨ ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ .......... 15

គ.៩ ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ........................................................................17

គ.១០ ផែនការផ្សព្វផ្សាយ បណ្ដុះបណ្ដាល បង្កើនការយល់ដឹង ........................................................18

គ.១១ ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ................................................................19

ឃ. យុទ្ធសាស្ត្រ ..........................................................................................................................20

តារាងឧបសម្ព័ន្ធ ៖ តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឃុំចំណាក្រោម រយៈពេល (២០១៧ ដល់ ២០១៩)..........................................................................................................................២០

តារាងឧបសម្ព័ន្ធ ៖ តារាងកម្មវិធីការងារ ........................................................................................២៦

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទអភិវឌ្ឍន៍ស្ពានគ្រង ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៦ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០០៧ និងលើកទី ២ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៤។

សហគមន៍នេសាទអភិវឌ្ឍន៍ស្ពានគ្រង មានទីតាំងស្ថិតនៅភូមិ ស្ពានគ្រង ឃុំ ចំណាក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ ដែលមានសមាជិកសរុបចំនួន ៣១៥ នាក់ ស្ត្រីចំនួន១៤៩នាក់ និងមានគណៈកម្មការចំនួន ៩នាក់ ស្ត្រីចំនួន ០២នាក់ ក្នុងនោះចំនួនគ្រួសារសរុបចំនួន ២៨៧ គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមាន:

- បានរៀបចំបណ្តាញសហគមន៍បានចំនួន ២នាក់ ។
- បានរៀបចំក្រុមល្បាតបានចំនួន ០១ក្រុម និងធ្វើការចុះល្បាតជាប្រចាំឆ្នាំ។
- បានរៀបចំក្រុមសន្សំបានចំនួន ០៤ក្រុម ដែលមានសមាជិកសរុបចំនួន ៩៨នាក់ ស្ត្រី ៧៨នាក់។
- បានរៀបចំទីស្នាក់ការសហគមន៍នេសាទចំនួន ០១ខ្នង ដែលមានការឧបត្ថម្ភពីអង្គការ OGB ។
- បានទិញកាណូតល្បាត ០១គ្រឿង ម៉ាស៊ីន ០១ គ្រឿងស៊ីមែល ០១ គ្រឿង និងបានធ្វើស្លាកសញ្ញាផ្សព្វផ្សាយដែលមានការឧបត្ថម្ភពីអង្គការ OGB។
- បានរៀបចំជាស្តង់ប្រមូលទិញផលនេសាទបាន ០១ ខ្នង ដែលមានការឧបត្ថម្ភពីអង្គការ OGB។
- បានធ្វើអណ្តូងដាក់លូជូនប្រជាពលរដ្ឋចំនួន ០៤អណ្តូង។
- បានប្រជុំពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ អាជ្ញាធរភូមិ ឃុំ សមត្ថកិច្ចរដ្ឋបាលជលផល និងអ្នកពាក់ព័ន្ធដើម្បីរៀបចំកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍ ។
- ផ្សព្វផ្សាយអំពីលិខិតបទដ្ឋានពាក់ព័ន្ធនឹងសហគមន៍នេសាទដល់សមាជិកសហគមន៍នេសាទ និងអ្នកចូលរួមមកប្រើប្រាស់ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍។
- សហការជាមួយអាជ្ញាធរភូមិ ឃុំ និងសមត្ថកិច្ចរដ្ឋបាលជលផល ចុះល្បាត ការពារ ទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍។
- ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ និងទទួលពាក្យសុំចូលជាសមាជិកសហគមន៍នេសាទដោយស្ម័គ្រចិត្តបង់ប្រាក់សមាជិកភាពរបស់សហគមន៍នេសាទ។
- រៀបចំសេចក្តីព្រៀងកន្លែងសហគមន៍នេសាទ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទជាមួយខណ្ឌរដ្ឋបាលជលផល
- បានផ្សព្វផ្សាយបង្កើនការយល់ដឹង អំពីផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំពុល សារៈប្រយោជន៍ព្រៃលិចទឹក និងការផ្សព្វផ្សាយច្បាប់ជលផល។
- បានបើកវគ្គបណ្តុះបណ្តាលខ្លីៗ អំពីការចិញ្ចឹមត្រី ដាំផ្សិត ចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក ការអប់រំសុខភាព អំពើហឹង្សាក្នុងគ្រួសារ យេនឌ័រក្នុងការអភិវឌ្ឍន៍សហគមន៍ ការគ្រប់គ្រងធនធានធនធានធម្មជាតិ ការកែច្នៃផលនេសាទ ដែលឧបត្ថម្ភផលនេសាទ។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក- ប្រជាពលរដ្ឋ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន ២.២៨០នាក់ ប្រុស ១.០៩៤នាក់ ស្រី១.១៨៦នាក់ ។ ក្នុងនោះមានជនជាតិខ្មែរចំនួន ២.២៨០នាក់ ខ្មែរអ៊ីស្លាមចំនួន០នាក់ និងអនិជនវៀតណាមចំនួន ០នាក់។ (Font Khmer battambang) (size 11)
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៨០នាក់ ពោះមាយ ៨នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ១៩នាក់ ស្រី ១៣នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ០៥នាក់ ស្រី ០៤នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន០២នាក់ ស្រី០២ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់ព្រះពុទ្ធសាសនា៩៩% ។ ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ីស្លាម ប្រមាណ ០% និងសាសនាកាតូលិកប្រមាណ ០១%
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ២២៨នាក់ ស្រី ១៣៦នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ២១៤នាក់ ស្រី ៦៩នាក់ កំរិតមធ្យមសិក្សាចំនួន ៥៧០នាក់ ស្រី ២៥៦នាក់ និងថ្នាក់កំរិតឧត្តមសិក្សា ២០នាក់ ស្រី ១០នាក់ ។

### ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- ធ្វើនេសាទចំនួន ៩០%
- ធ្វើស្រែ ១០០%
- ធ្វើវារីវប្បកម្ម ចំនួន០៥គ្រួសារ ០៥កន្លែងទំហំ ៤០០ម៉ែត្រការ៉េ
- ដាំបន្លែចំនួន ១៥គ្រួសារ ទំហំ ០២ហិចតា
- ជាងផ្ទះចំនួន ០៥គ្រួសារ
- លក់ដូរចំនួន ១០០គ្រួសារ
- កែច្នៃផលនេសាទ ០៧គ្រួសារ
- ទិញត្រីចំនួន ០៧គ្រួសារ
- ចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ៩០%
- រត់ម៉ូតូឌុប ០៣គ្រួសារ
- រត់តាក់ស៊ី ០៣គ្រួសារ
- ឡើងត្នោត ០៨គ្រួសារ
- មេចុងភៅ ០៣គ្រួសារ
- ស៊ីឈ្នួល ៦០% នៃអ្នកភូមិ
- ពេទ្យសត្វ០១ នាក់
- ជាងជួសជុលម៉ាស៊ីន ១០នាក់
- ផ្សារដែក ០៤នាក់

- ជាងកាត់សក់ ០២នាក់
- ជាងកាត់ដេរ ០៦នាក់
- លាងម៉ូតូ ១០ នាក់
- គ្រូបុរាណ ០៥នាក់
- កម្មកររោងចក្រ ២៤០ នាក់

## ៣. កន្លែងនេសាទសហគមន៍ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍អភិវឌ្ឍន៍ស្ពានគ្រង ជាកន្លែងដែលត្រូវបានកាត់បន្ថយចេញពីឡូត៍នេសាទលេខ៤និងដែននេសាទទឹកសាប។

កន្លែងនេសាទសហគមន៍ **អភិវឌ្ឍន៍ស្ពានគ្រង** មានទំហំ ២១២២ ហិកតា និងមានកំណត់និយាមកា ដូចមានចែងក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់:

- ខាងជើងទល់នឹង ចំណុចផ្លូវបំបែកអូរភេ
- ខាងត្បូងទល់នឹង ចំណុចវាល គ្រពាំងប៉ានស្រោត
- ខាងកើតទល់នឹង សហគមន៍នេសាទសាមគ្គីអភិវឌ្ឍន៍បឹងខ្សែខ្លែងកក់ធំ
- ខាងលិចទល់នឹង សហគមន៍នេសាទនាងណយតាពីសាមគ្គីស្វាយអៀរ

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍អភិវឌ្ឍន៍ស្ពានគ្រងមានបឹងចំនួន០៤ គ្រពាំងចំនួន១៣បៀរចំនួន៥០ និងស្រះ ចំនួន០៥នាក់។

- បឹង កំព្រីង ទំហំ ៣,១៩ ហត នេសាទពីខែ ១២ ដល់ខែ ០៤
- បឹងត្រឡាចទំហំ ៣,៨៣ហត នេសាទពីខែ ១២ ដល់ខែ ១១
- បឹង ពាក់ថែបក្រៅទំហំ ១,៣៨ហត នេសាទពីខែ ១២ ដល់ខែ ១១
- គ្រពាំងស្បូវទំហំ ០,១៥ហត នេសាទពីខែ ០១ ដល់ខែ ០៣
- គ្រពាំងសណ្តាន់ទំហំ ០,៣៨ហត នេសាទពីខែ ០១ ដល់ខែ ១២
- គ្រពាំងទំលាក់តាងទំហំ ០,៥៦ហត នេសាទពីខែ ០១ ដល់ខែ ០៤
- គ្រពាំងអាណុបទំហំ ២,៩៨ហត នេសាទពីខែ ០១ ដល់ខែ ០៤
- គ្រពាំងភ្លោះបីទំហំ ០,៣១ហត នេសាទពីខែ០១ ដល់ខែ ១១
- គ្រពាំងបាក់ស្មែងទំហំ ០,៣៨ហត នេសាទពីខែ ០១ ដល់ខែ ១២
- គ្រពាំងបែកចានទំហំ ២,២២ហត នេសាទពីខែ ០១ ដល់ខែ០៤
- គ្រពាំងដំណាក់គ្រពាំងវែងទំហំ ៣,៥៧ ហត នេសាទពីខែ ០១ ដល់ខែ ០៤
- គ្រពាំង អាគ្រាវ ទំហំ ០,៦៧ ហត នេសាទពីខែ ០១ ដល់ខែ ១២
- គ្រពាំងរៀមទំហំ ១,១៥ហត នេសាទពីខែ ០១ ដល់ខែ ០៤

- ត្រពាំងរាំងប្រហោងទំហំ ១,០៤ហត នេសាទពីខែ ០១ ដល់ខែ ១២
- ត្រពាំងអន្សងបក ទំហំ ០,៥៦ហត នេសាទពីខែ០១ ដល់ខែ០៤
- ត្រពាំងអាពតទំហំ ០,៥៦ ហត នេសាទពីខែ ០១ ដល់ខែ ០៤
- ត្រពាំងត្រសែងធំ ទំហំ ១,៣ហត នេសាទពីខែ ០១ ដល់០៣
- ត្រពាំងកន្ទ្រប់ ទំហំ ១,៣ ហត នេសាទពីខែ ០១ ដល់ ១២
- ត្រពាំងច្រាំងក្រហម ទំហំ ១,០៤ហត នេសាទពីខែ ០១ ដល់ ១២
- ត្រពាំង ស្វាពាក់ចង់ទំហំ ០,៥២ហត នេសាទ ពីខែ០១ ដល់១២
- ត្រពាំងចកសាវាយទំហំ ០,៨១ហត នេសាទ ពីខែ០១ ដល់ខែ ០៣
- ត្រពាំងអង្រ្កងទំហំ ០,២៩ហត នេសាទពីខែ០១ ដល់ខែ ០៣
- ត្រពាំងតាលួងទំហំ ០,៦៨ហត នេសាទពីខែ ០១ ដល់ខែ ១២
- ត្រពាំងប្រលិតទំហំ ៦២៥,២៤៥ ហត
- កន្លែងត្រូវដាំព្រៃលិចទឹកឡើងវិញ(វាលជុំវិញបឹងពាក់ថែបក្រៅ) ទំហំ ៥,០០ហត

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- បឹងពាក់ថែបក្រៅទាំងមូលទំហំ ១,៣៨ហត
- កន្លែងអភិរក្សព្រៃលិចទឹក(ព្រៃអភិរក្សពាក់ថែបក្រៅ) ទំហំ ៦៦,៣៥ហត។

ឃ. ធនធានជលផល

- **ប្រភេទត្រី** ( ត្រីឆ្តោ រ៉ស់ ខ្មាន់ កំភ្លាញ រៀល ឆ្ពិន ក្រាញ់ កញ្ចុះ តាអោន ឆ្លាំង កន្ទ្រប់ ត្រំ ក្អែក ព្រួល ត្រសក់ កន្ត្រង ព្រូង ក្រុស ក្រហែ កញ្ច្រូក ស្រកាក្តាម ស្លឹកឬស្សី ឆ្លូញ ដំរី អណ្តាតឆ្កែ លិញ ប្រម៉ា កញ្ចុះក្តោង ច្រកែង ផ្ទៀត កំភ្លៀវ អណ្តែង ត្បក ស្រកៀតស្រង់ ប្រា ពោ ស្លាត ក្រាយ គ្រីម កំព្រាម កញ្ចនជ័យ កញ្ចុះក្របី ខ្ចឹង កញ្ចុះជ្រូក ត្រនេល ព្រលូង កេស ក្រម៉ម គល់រាំង ចង្វារ ត្រចៀកស្លា ដងខ្មែង ឆ្តោក កាបក្បាលធំ និងកន្ទ្រប់ខ្លា.......)
- **ប្រភេទវារីសត្វ** ( អណ្តើក ពស់ព្រលិត ពស់ត្រី ក្តាម ខ្យង ខ្ចៅ អន្ទង់ កន្ធាយ អន្សង ត្រំ លៀស កំពឹស......)
- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារុក្ខជាតិ** (រាំង ក្រស់ ត្រសែង ត្នូ ផ្ទោល ទៀនព្រៃ ឈ្លើយ ញ. រាំ ផ្ទូរ ត្រពស់ សំរ៉ែក សង្ស៊ុរ ភ្នំភ្លើង ថ្ងាន់ ភ្អែកព្រាប ខ្លាយមាន់ ថ្លើមអណ្តើក អញ្ចាញ ច្រកែង សណ្តាន់ រំដិញ អាវក្រពើ ត្រដក់ ប្រផិញ ចាប៉ូវ ចាទៃ ផ្កាប់ ត្រឡុក បាយដំណើប វល្លិព្រេង គ្រដិត បន្លាយូន កណ្តាប់ចង្អេរ ឆ្អឹងពស់ មុខឈ្មាង ស្មៅ ក្រទាំងហៃ ឈូក ស្តន់ កំពីងពួយ ដើមវៃ ស្លត បបោស ព្រលិត ត្រកួន កំប្លោក ស្រងែ ស្លាបទា កាឆែត កំពីងពួយ សារ៉ាយ ចក ចំផ្លង...... ) ។
- **ប្រភេទល្មូន សត្វស្លាបទឹក សត្វផ្សេងៗ**
(កុកស, កុកក្រក, មាន់ទឹក, ទោម, ប្រវឹក, ខ្លុំ, ទាព្រៃ, វនាល, ខ្យង, ក្រសារ, ត្រដក់, ស្វារ, កេ, ខ្លាត្រី-ក្អែកទឹក, ស្មោញ, អក, អែអត, ក្អែកគោក, ក្អុកទឹក, ពស់........)។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៣១៥ នាក់ ស្រី ១១៥នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍ចំនួន ៤៩៥នាក់ ស្រី ២៩១នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិក ដែលមកពីក្រៅសហគមន៍មានចំនួន៣០០នាក់ ស្រី១៥០នាក់។

### ខ. ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកកាណូតសហគមន៍:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ដៃ(៩០ម) | ៥៨x៥០ន | -ក្រឡា=២,៥ស.ម<br>-សំរុង=២ម<br>-ប្រវែង=២២.៥០០ម | ខែ៦ ទៅ ខែ ២ |
| សន្ទូចរនែង | ផ្លែ | ៥០០ផx១២ន | - ផ្លែលេខ=១៤-១៦<br>- ចំនួន=៦០០០ផ្លែ | [illegible] |
| ព្រយ៉ុង | វង់(៣០ម) | ១៥នx៣០ម | - ក្រឡា ២,៥ ស.ម<br>- សំរុង ៥ម<br>- ប្រវែង ៤៥០ម | [illegible] |
| អួន | វង់(៤០ម) | ៧នx៤០ម | - ក្រឡា ២,៥ ស.ម<br>- សំរុង ៥ម<br>- ប្រវែង ២៨០ម | [illegible] |
| សំណាញ់ | វង់ | ១៥នx១វង់ | - ក្រឡា=១.៥សម<br>- សំរុង=៦ម | [illegible] |
| អញ្ចាង | វង់ | ១០នx១វង់ | - ទទឹង= ២ម<br>- បណ្ដោយ=៣ម<br>- សំរុង=១៥ម | [illegible] |
| ទ្រូកញ្ចុះ | គ្រឿង | ៥នx១៥ន | - ទទឹង= ៤០ស.ម<br>- បណ្ដោយ= ១ម<br>- ចំនួន ៧៥គ | [illegible] |
| លបទល់ | គ្រឿង | ៦នx៥០ម | - ទទឹង= ៤០ស.ម<br>- បណ្ដោយ= ១ម<br>- ចំនួន ៣០០គ | ខែ១១ ទៅ ខែ ១ |

| | | | | |
|---|---|---|---|---|
| លបលូង | គ្រឿង | ៨នx២០គ | - ទទឹង= ៤០ស.ម<br>- បណ្ដោយ= ១ម<br>- ចំនួន ១៦០គ | ខែ១ ទៅ ខែ ៦ |
| ជុច | គ្រឿង | ៥នx១២០ម | - ចំនួន ៦០០គ | ខែ១២ ទៅ ខែ ២ |
| អង្រុត | គ្រឿង | ១០នx១គ | - ចំនួន ១០គ | ខែ១ ទៅ ខែ ១២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំ ឬចែវ | ២០៣គ្រឿង | ៤០០-៦០០គីឡូក្រាម | |
| ទូកបាឡាភ្ជាប់ម៉ាស៊ីន | ២៧គ្រឿង | ១តោន | ១២-១៨ សេះ |
| ទូកកំពោលភ្ជាប់ម៉ាស៊ីនជជុះ | ៥០គ្រឿង | ៦០០គ.ក | ៦-១២ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ដៃ(៩០ម) | ៥៨x២០ន | -ក្រឡា=២,៥ស.ម<br>-សំរុង=២ម<br>-ប្រវែង=៩០០០ម | ខែ៦ ទៅ ខែ ២ |
| សន្ទូចរនង | ផ្លែ | ៣០០៨x១២ន | - ផ្លែលេខ=១៤-១៦<br>- ចំនួន=៣៦០០ផ្លែ | ខែ៦ ទៅ ខែ ២ |
| អួន | វង់(៤០ម) | ២នx៤០ម | - ក្រឡា ២,៥ ស.ម<br>- សំរុង ៥ម<br>- ប្រវែង ៨០ម | ខែ២-ខែ៥ |
| សំណាញ់ | វង់ | ១៥នx១វង់ | - ក្រឡា=១.៥សម<br>- សំរុង=៦ម | ខែ១ ទៅ ខែ ៤ |
| អញ្ចង | វង | ១០នx១វង់ | - ទទឹង= ២ម<br>- បណ្ដោយ=៣ម<br>- សំរុង=១៥ម | ខែ១ ទៅ ខែ ៤ |
| ទ្រូកញ្ចុះ | គ្រឿង | ៥នx១៥ន | - ទទឹង= ៤០ស.ម<br>- បណ្ដោយ= ១ម<br>- ចំនួន ៧៥គ | ខែ៧ ទៅ ខែ ៩ |
| លបទល់ | គ្រឿង | ៣នx៤០ម | - ទទឹង= ៤០ស.ម<br>- បណ្ដោយ= ១ម<br>- ចំនួន ១២០គ | ខែ១១ ទៅ ខែ ១ |
| លបលូង | គ្រឿង | ៨នx២០ម | - ទទឹង= ៤០ស.ម<br>- បណ្ដោយ= ១ម | ខែ១ ទៅ ខែ ៦ |

| | | | | |
|---|---|---|---|---|
| | | | - ចំនួន ១៦០គ | |
| ផុច | គ្រឿង | ៥នx១២០គ | - ចំនួន ៦០០គ | ខែ១២ ទៅ ខែ ២ |
| អង្រុត | គ្រឿង | ១០នx១គ.ក | - ចំនួន ១០គ | ខែ១ ទៅ ខែ ១២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំ ឬចែវ | ៥០គ្រឿង | ៤០០-៦០០គីឡូក្រាម | |
| ប៉ាឡាភ្ជាប់ទូកម៉ាស៊ីន | ៥០គ្រឿង | ១តោន | ៦-១២ សេះ |
| ទូកកំពេលភ្ជាប់ម៉ាស៊ីនជជុះ | ៥០គ្រឿង | ៦០០គ.ក | ៦០០ |

គ. ប៉ាន់ប្រម៉ាណផលចាប់ផលនេសាទប្រចាំឆ្នាំ

| ប្រភេទលផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ២៥០គ.ក | ៥០គ.ក | ៣០០គ.ក |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទអភិវឌ្ឍន៍ស្ពានគ្រង មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាសហគមន៍ ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ដែលបានកាត់បន្ថយពីនាទីឡូត៍នេសាទលេខ១របស់ខេត្តកំពង់ធំ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើការនេសាទជាប្រពៃណី និងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើអោយប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួមដើម្បីអោយប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ពីសារៈសំខាន់ពីធនធានជលផល ធ្វើជាម្ចាស់គ្រប់គ្រង និងប្រើប្រាស់ដោយផ្ទាល់ ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំង/កន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតអោយប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| - បឹងត្រឡាច<br>- បឹងកំព្រីង<br>- ត្រពាំងអាណុប<br>- ត្រពាំងបែកចាន<br>- ដំណាក់ត្រពាំងវែង | ខែ១២-ខែ៥ | មង | -ក្រឡាចាប់ពី២,៥ស.ម<br>-ប្រវែង=៩០ម | ០៤នាក់=៣៦០ម | បឹង និងត្រពាំងធំៗ |
| | | ប៉ោង | -៥ គ | ៤នាក់ | |
| | | លាន់ | ៥គ | ១០នាក់ | |
| | | អង្រុត | -១០គ | ១០នាក់ | |
| | | ព្រយ៉ុង | - ក្រឡាចាប់ពី២.៥ស.ម<br>- សំរុង ៥ម<br>- ប្រវែង=៣០ម | ២នាក់=៦០ម | |
| | | សន្ទូច | - ផ្លែលេខ១៤-១៨<br>- ចំនួន=១០០ផ | ២នាក់=២០០ផ | |
| | | បបក់ | - ៣ន | ៣ន | |
| | | បង្គៃ | - ផ្លែលេខ១៤-១៨<br>- ចំនួន=១០០ផ | ៣ន=៣០០ផ | |
| - ត្រពាំងរាំងបហោង<br>- ត្រពាំងអន្សង់បក<br>- ត្រពាំងត្រសែងធំ<br>- ត្រពាំងកន្ទប់<br>- ត្រពាំងរៀម<br>- ត្រពាំងប្រាំងក្រហម | ខែ១-ខែ៥ | មង | -ក្រឡាចាប់ពី២.៥ស.ម<br>- សំរុង៥ម<br>-ប្រវែង=២០ម | ២នាក់=១៤០ម | ត្រពាំងទំហំមធ្យម |
| | | ប៉ោង | -១០គ | ៣នាក់ | |
| | | លាន់ | - ១០គ | ២នាក់ | |
| | | អង្រុត | -៧គ | ៧នាក់ | |
| | | ព្រយ៉ុង | -ក្រឡា ២.៥ហ៊ុន<br>-សំរុង៥ម<br>-ប្រវែង=២០ម | ១ន=២០ម | |
| | | សន្ទូច | - ផ្លែលេខ១៤-១៨<br>- ចំនួន=១០០ផ | ២ន=២០០ផ | |
| | | ប្របក់ | - ៣ផ | ៣ន | |
| | | បង្គៃ | ផ្លែលេខ ១៤-១៨<br>ចំនួន ១០០ផ | ២ន | |

| | | | | | |
|---|---|---|---|---|---|
| | | សំណាញ់ | - ក្រឡា=១.៥សម<br>- សំរុង=៦ម | ២ន | |
| ទំនាបលិចទឹករដូវវស្សា | ខែ៧-ខែ១១ | មង | -ក្រឡាចាប់ពី២.៥ស.ម ឡើងទៅ<br>- សំរុង២ម<br>-ប្រវែង=១៨០ម | ២នាក់=៣៦០ម | |
| | | ប៉ោង | -១០គ | ១០នាក់=១០០គ | |
| | | លាន់ | - ១០គ | ១០នាក់=១៥០គ | |
| | | សន្ទូច | - ផ្លែលេខ១៤-១៨<br>- ចំនួន=១០០ម | ២ន=២០០ផ | |
| | | ប្របក់ | - ១ផ | ៣ន | |
| | | បង្គៃ | ផ្លែលេខ ១៤-១៨<br>ចំនួន ២០ផ | ២ន | |
| | | លាន់ | - ២០គ | ២នាក់=២០ | |
| | | អង្រុត | -៧គ | ៧នាក់=៧គ | |

គ.២ ផែនការកែលម្អដែននេសាទ

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងកំព្រីង | ១.៥ហិចតា | ១.៥ហិចតា ជំរៅ ១ម | -ស្វែងរកថវិការ ដើម្បីគាំទ្រការជីកបឹងនិងរៀបចំកន្លែងនេសាទ<br>-រៀបចំផែនការ និងប្រមូលកំលាំងប្រជានេសាទដើម្បី រៀបចំកន្លែង នេសាទ<br>-អនុវត្តសកម្មភាព | ០១.០១.១៧ | ០១.០១.១៨ | សុំជំនួយ |

### គ.៣ ផែនការកែលំអរ និងរៀបចំកន្លែងអភិរក្ស

#### គ.៣.១ អភិរក្សត្រីពូជ

ការរៀបចំកន្លែងអភិរក្ស និងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងពាក់ថៃបក្រៅ | ផ្ទៃបឹងទាំងមូលទំហំ ១.៣៨ហត | - ពូជត្រីគ្រប់ប្រភេទ<br>- សត្វទឹកគ្រប់ប្រភេទ | -កំណត់ព្រំប្រទល់កន្លែងអភិរក្ស បោះបង្គោលអភិរក្ស | ១/០៣/១៨ | ០១/០៤/១៨ | |
| | | | - ដាក់ស្លាកសញ្ញាហាមឃាត់ | ០១/០៥/១៧ | ០១/០៧/១៧ | |
| | | | -ដាក់ជម្រកត្រីសិប្បនិមិត្ត | ០១/០៦/១៧ | ០១/០៧/១៧ | |
| | | | -លែងកូនត្រី | ០១/០៨/១៧ | ០១/០៨/១៧ | |
| | | | -ផ្សព្វផ្សាយសារៈប្រយោជន៍កន្លែងអភិរក្ស | ០១/០៨/១៧ | ០១/០៨/១៧ | |
| | | | -សង់រោងយាម(៦មx៥ម) | ០១/០៦/១៨ | ០១/០៧/១៨ | |
| | | | -រៀបចំក្រុមល្បាត ចុះល្បាតជាប្រចាំ | ០១/០៨/១៧ | ០១/០៨/១៧ | |
| | | | -ស្តារត្រពាំង(៥០មx៥០ម)<br>- ជំរៅ ២ម | ០១/០៣/១៨ | ០១/០៥/១៨ | |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

#### គ.៤.១ ផែនការដាំព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមានក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ព្រៃអភិរក្សពាក់ថៃបក្រៅ | ទំហំ ៧២.៣៥ ហត | - សត្វគ្រប់ប្រភេទក្នុងតំបន់<br>- ព្រៃលិចទឹកគ្រប់ប្រភេទ | -ដាំព្រៃលិចទឹក<br>-ដាក់ស្លាកសញ្ញា(ថ្មី)<br>-ហាមកាប់ព្រៃ | ១/៦/២០១៨ | ១/៧/២០១៨ | |

## គ. ៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវអភិវឌ្ឍន៍ដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីក្នុងស្រះ | ០៤ស្រះ ទំហំ ១០មx១៥ម(២០ គ្រួសារ) | ត្រីអណ្តែង, ត្រីក្រាញ់ | ២០០០០ (១ស្រះ=១០០០ ក្បាល) | ០៧/២០១៧ | ១២/២០១៧ |
| ចិញ្ចឹមត្រីក្នុងបែរ (បណ្តោយ=១០ម, ទទឹង១០ម | ១០ | ត្រីអណ្តែង, ត្រីក្រាញ់ | ១០០០០ (១ស្រះ=១០០០) | ០៧/២០១៧ | ១២/២០១៧ |

## គ. ៦ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ១០បង្គោល | តាមផែនទីសហគមន៍ | គណៈកម្មការសហគមន៍នេសាទ | ខែ ០២/២០១៨ | ខែ០៣/២០១៨ | ជំនួយពីអង្គការ |

## គ. ៧ ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ប្រមូលផល | ផ្សេងៗ |
|---|---|---|---|---|
| ចិញ្ចឹមមាន់ ៥គ្រួសារ | -ជ្រើសរើសសមាជិកសហគមនគម្រូ<br>-បណ្តុះបណ្តាលបច្ចេកទេស<br>-សង់ទ្រុងមាន់<br>-ផ្តល់ពូជមាន់<br>-អនុវត្តន៍ការចិញ្ចឹមតាមបច្ចេកទេស | ២០១៧ | ២០១៧ | |
| ដាំបន្លែ ៥គ្រួសារ | -ជ្រើសរើសសមាជិកសហគមន៍គម្រូ<br>-បណ្តុះបណ្តាលបច្ចេកទេស<br>-ជ្រើសរើសកន្លែង និងរៀបចំសួនបន្លែគម្រូ<br>-អនុវត្តការដាំតាមបច្ចេកទេស | ២០១៧ | ២០១៧ | |

## គ. ៨ ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ

### គ.៨.១ ការបង្កើតក្រុមសន្សំប្រាក់ និងស្តង់ទិញលក់ផលត្រី

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល | ផ្សេងៗ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំ និងប្រាក់កម្ចី | - ផ្សព្វផ្សាយផលប្រយោជន៍ការបង្កើតក្រុមសន្សំប្រាក់<br>- ចងក្រងក្រុមសន្សំប្រាក់<br>- រៀបចំបទបញ្ជាផ្ទៃក្នុង និងគោលការណ៍ក្រុមសន្សំប្រាក់<br>- ផ្តល់ទុន<br>- អនុវត្តការសន្សំប្រាក់<br>- តាមដាន និងត្រួតពិនិត្យ | ២០១៨ | ២០១៨ | សុំជំនួយ |
| បង្កើតស្តង់ប្រមូលទិញ និងលក់ផលនេសាទ | -ស្វែងរកមូលនិធិដើម្បីសង់ស្តង់ផលនេសាទ<br>-រៀបចំផែនការសាងសង់ស្តង់ផលនេសាទ<br>-ទិញសម្ភារៈសម្រាប់សាងសង់ស្តង់ផលនេសាទ<br>-អនុវត្តការសាងសង់ស្តង់ផលនេសាទ<br>-បង្កើតគណៈកម្មការគ្រប់គ្រងស្តង់ និងលក្ខន្តិកៈគ្រប់គ្រង<br>-ស្វែងរកទុនដើម្បីទិញផលនេសាទ និងអនុវត្តន៍ការទទួលទិញ និងលក់ផលនេសាទ<br>-តាមដាន និងត្រួតពិនិត្យ | ២០១៨ | ២០១៨ | សុំជំនួយ |

### គ.៨.២ ការចិញ្ចឹមជ្រូក

| ចំនួនអ្នកចិញ្ចឹមជ្រូក | សកម្មភាព | ចំនួនទ្រុងជ្រូក | បរិមាណកូនជ្រូក | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ១០គ្រួសារ | -ប្រជុំរៀបចំក្រុមចិញ្ចឹមជ្រូកដែលជាសមាជិកមានជីវភាពក្រីក្រ<br>-បណ្តុះបណ្តាលបច្ចេកទេស និងឯកសារចិញ្ចឹមជ្រូក<br>-ផ្តល់ប្រាក់កម្ចីចិញ្ចឹមជ្រូក<br>-ចូលរួមជួយធ្វើទ្រុងជ្រូក<br>-ជួយទិញ និងផ្តល់កូនជ្រូកអោយសមាជិកសហគមន៍នេសាទ<br>-តាមដាន និងវាយតម្លៃសកម្មភាពចិញ្ចឹមជ្រូក | ១០ | ៤០ | ១/១២/2017 | ១/៤/២០១៨ |

| | | | | | |
|---|---|---|---|---|---|
| | -ប្រមូលប្រាក់ដើមពីសមាជិកដែលបានខ្ចី<br>-ប្រជុំផ្សព្វផ្សាយ និងប្រគល់អោយសមាជិកសហគមន៍ត្រីក្រផ្សេងចិញ្ចឹមជ្រូកបន្ត | | | | |

### គ.៨.៣ ការចិញ្ចឹមមាន់

| ចំនួនអ្នកចិញ្ចឹមមាន់ | សកម្មភាព | ចំនួនទ្រុងមាន់ | បរិមាណកូនមាន់ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ១០គ្រួសារ | -ប្រជុំរៀបចំក្រុមចិញ្ចឹមមាន់ដែលជាសមាជិកមានជីវភាពក្រីក្រ<br>-បណ្តុះបណ្តាលបច្ចេកទេស និងឯកសារចិញ្ចឹមមាន់<br>-ផ្តល់ប្រាក់កម្ចីចិញ្ចឹមមាន់<br>-ចូលរួមជួយធ្វើទ្រុងជ្រូក<br>-ជួយទិញ និងផ្តល់កូនមាន់អោយសមាជិកសហគមន៍នេសាទ<br>-តាមដាន និងវាយតម្លៃសកម្មភាពចិញ្ចឹមមាន់<br>-ប្រមូលប្រាក់ដើមពីសមាជិកដែលបានខ្ចី<br>-ប្រជុំផ្សព្វផ្សាយ និងប្រគល់អោយសមាជិកសហគមន៍ក្រីក្រផ្សេងចិញ្ចឹមមាន់បន្ត | ១០ | ១២០ | ១/៨/២០១៧ | ១/២/២០១៨ |

### គ.៨.៤ ការធ្វើត្រីឆ្អើរ

| ចំនួនអ្នកធ្វើត្រីឆ្អើរ | សកម្មភាព | ប្រភេទត្រី | ខែ/ ឆ្នាំ | |
|---|---|---|---|---|
| | | | ចាប់ផ្តើម | ប្រមូលផល |
| ១០គ្រួសារ | - ប្រជុំរៀបចំក្រុមធ្វើត្រីឆ្អើរ<br>- បណ្តុះបណ្តាលបច្ចេកទេសនិងឯកសារអំពីគុណភាពឆ្អើរត្រី<br>- តាមដាន និងវាយតម្លៃសកម្មភាព | - ត្រីកញ្ចុះ<br>- ត្រីរៀល<br>- ត្រីក្រុស<br>- ត្រីភ្ជាអោន | ១/១/២០១៨ | ១/៨/២០១៨ |

| | | | | |
|---|---|---|---|---|
| | ឆ្អើរត្រី<br>- ប្រមូលប្រាក់ដើមពីសមាជិកសហគមន៍ដែលបានខ្ចីទិញត្រីធ្វើត្រីឆ្អើរ<br>- ប្រជុំផ្សព្វផ្សាយ និងប្រគល់អោយសមាជិកសហគមន៍ខ្ចីបន្ត | - ត្រីកំភ្លាវ | | |

គ. ៨.៥ ការធ្វើប្រហុក

| ចំនួនអ្នកធ្វើត្រីប្រហុក | សកម្មភាព | ប្រភេទត្រី | ខែ/ ឆ្នាំ | |
|---|---|---|---|---|
| | | | ចាប់ផ្តើម | ប្រមូលផល |
| ២០គ្រួសារ | - ប្រជុំរៀបចំក្រុមធ្វើប្រហុក<br>- បណ្តុះបណ្តាលបច្ចេកទេស និងឯកសារអំពីគុណភាពប្រហុក<br>- តាមដាន និងវាយតម្លៃសកម្មភាពធ្វើប្រហុក<br>- ប្រមូលប្រាក់ដើមពីសមាជិកសហគមន៍ដែលបានខ្ចីទិញត្រីធ្វើប្រហុកត្រីឆ្អើរ<br>- ប្រជុំផ្សព្វផ្សាយ និងប្រគល់អោយសមាជិកសហគមន៍ខ្ចីបន្ត។ | - ត្រីរៀល<br>- ត្រីក្រុស | ១/១២/២០១៧ | ១/៦/២០១៨ |

គ.៩ ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

| ប្រភេទវគ្គបណ្តុះបណ្តាល | គ្រូបង្គោល | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| របៀបនៃការគ្រប់គ្រងសហគមន៍នេសាទ | រដ្ឋបាលជលផល | កក្កដា ២០១៧ | កក្កដា ២០១៧ | ៣ថ្ងៃ |
| វិធីសាស្រ្តផ្សព្វផ្សាយ | រដ្ឋបាលជលផល | សីហា ២០១៧ | សីហា ២០១៧ | ៣ថ្ងៃ |
| ការកសាងភាពជាដៃគូរ និងបណ្តាញ | រដ្ឋបាលជលផល | កញ្ញា ២០១៧ | កញ្ញា ២០១៧ | ៣ថ្ងៃ |
| វិធីសាស្រ្តស្វែងថវិកា និងការសរសេរគម្រោងសំណើសុំថវិកា | រដ្ឋបាលជលផល | តុលា ២០១៧ | តុលា ២០១៧ | ៣ថ្ងៃ |
| ច្បាប់ស្តីពីជលផល | រដ្ឋបាលជលផល | វិច្ឆិកា ២០១៧ | វិច្ឆិកា ២០១៧ | ៣ថ្ងៃ |
| វិធីសាស្រ្តដោះស្រាយទំនាស់ | រដ្ឋបាលជលផល | ធ្នូ ២០១៧ | ធ្នូ ២០១៧ | ៣ថ្ងៃ |
| ជំនាញក្នុងការសម្របសម្រួល និងការ | រដ្ឋបាលជលផល | មករា ២០១៨ | មករា ២០១៨ | ៣ថ្ងៃ |

| | | | | |
|---|---|---|---|---|
| តៀងគរអោយមានការចូលរួមក្នុងសហគមន៍ | | | | |
| ជំនាញក្នុងការទំនាក់ទំនង | រដ្ឋបាលជលផល | កុម្ភៈ ២០១៨ | កុម្ភៈ ២០១៨ | ៣ថ្ងៃ |

### គ.១០ ផែនការផ្សព្វផ្សាយ បណ្តុះបណ្តាល បង្កើនការយល់ដឹង

| ផែនការ | សកម្មភាព | ថ្ងៃខែចាប់ផ្តើម | ថ្ងៃខែបញ្ចប់ | ក្រុមគោលដៅ | ផ្សេងៗ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ | លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២០១៧ | ២០១៧ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ផែនទី កំណត់ព្រំប្រទល់កន្លែងនេសាទ | ២០១៨ | ២០១៨ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ផែនការគ្រប់គ្រងកន្លែងនេសាទ | ២០១៧ | ២០១៩ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ច្បាប់ជលផល | ៧/២០១៧ | ២០១៩ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | សារៈប្រយោជន៍ព្រៃលិចទឹក | ៧/២០១៧ | ២០១៩ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ផលប៉ះពាល់ការប្រើប្រាស់សារធាតុគីមីពុល | ៧/២០១៧ | ២០១៩ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ការគ្រប់គ្រងកន្លែងអភិរក្ស | ៦/២០១៧ | ២០១៩ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | កម្មវិធីទឹកស្អាត សុខភាព អនាម័យ និងបរិស្ថានតាមមូលដ្ឋាន | ២០១៧ | ២០១៩ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| បណ្តុះបណ្តាល | វិធីសាស្ត្រនៃការចងក្រងក្រុមសន្សំប្រាក់ និងនីតិវិធីនៃ | ៧/២០១៧ | ៧/២០១៧ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |

| | | | | | |
|---|---|---|---|---|---|
| | ការសន្សំ | | | | |
| | ការកែច្នៃត្រីតាមស្តង់ដា (ប្រហុក ផ្អក ត្រីងៀត) | ២០១៧ | ២០១៧ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ការធ្វើកសិកម្មចម្រុះ | ២០១៨ | ២០១៨ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ, ជលផល |
| | ការចិញ្ចឹមត្រី | ២០១៧ | ២០១៨ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ,ឃុំ, ជលផល |
| | ការដោះស្រាយទំនាស់ | ៣/២០១៨ | ៣/២០១៩ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ |
| | កិច្ចការរដ្ឋបាល | ៤/២០១៨ | ៤/២០១៨ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ |
| | ការគ្រប់គ្រងហិរញ្ញវត្ថុ | ៤/២០១៨ | ២០១៩ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ, ឃុំ |
| | ការប្រែប្រួលអាកាសធាតុ និងសមភាពយេនឌ័រ | ៥/២០១៨ | ២០១៩ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ,ឃុំ |
| | គោលការណ៍ប្រើប្រាស់ថវិកាសហគមន៍ | ២០១៧ | ២០១៧ | គណៈកម្មការ សមាជិក និងអ្នកពាក់ព័ន្ធ | ស្នើសុំអង្គការ,ឃុំ |

### គ.១១ ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| វិភាគទានពីសមាជិកសហគមន៍ | - ផ្សព្វផ្សាយអំពីការដាក់ពាក្យសុំចូលជាសមាជិក<br>- ទទួលពាក្យសុំចូល និងប្រមូលប្រាក់បង់សមាជិកភាព | ១/៧/២០១៧ | ១/១២/២០១៧ | ២៣០០០០៛ | |
| វិភាគទានប្រចាំឆ្នាំ | - ផ្សព្វផ្សាយអំពីផលប្រយោជន៍ការបង់វិភាគទានប្រចាំឆ្នាំ<br>- ប្រមូលប្រាក់វិភាគទានប្រចាំឆ្នាំ | ១/៧/២០១៧ | ១/១២/២០១៨ | ២៧៦០០០៛ | |

| | | | | | |
|---|---|---|---|---|---|
| ជំនួយសប្បុរសជន និង អង្គការនានា | - រៀបចំធ្វើផែនការជាមួយក្រុមប្រឹក្សាចំណាក្រោម និងគម្រោងដើម្បីអភិវឌ្ឍន៍សហគមន៍នេសាទ | ១/៣/២០១៧ | ១/៦/២០១៧ | ១០០០០ដុល្លាអាមេរិក | |

ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការអោយទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងថវិកាទ្រទ្រង់ជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខន់ៗដើម្បីជុំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- គៀងគរអោយមានការការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានទប់ស្កាត់ការការហូរចូលអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឃុំចំណារក្រោម រយៈពេល (២០១៧ ដល់ ២០១៩)**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | -ប្រជុំផ្សព្វផ្សាយស្ដីពីការប្រើប្រាស់ឧបករណ៍នេសាទនៅតាមព្រែក ត្រពាំង និង អូរក្នុងកន្លែងនេសាទសហគមន៍។ | អ្នកនេសាទនឹងយល់ដឹងអំពីប្រភេទ ទំហំប្រវែងឧបករណ៍នេសាទដែលអនុញ្ញាតអោយប្រើប្រាស់ក្នុងកន្លែងនេសាទសហគមន៍នេសាទ។ | ៥០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និង គម្រោង SIFAL | ២០១៧ | ២០១៩ | |
| ២. កំណត់ និងរៀបចំកន្លែងអភិរក្សធ្វើ និងបោះបង្គោលក្នុងកន្លែងអភិរក្សព្រៃលិចទឹក និងត្រីមេពូជ | -ធ្វើស្លាកសញ្ញាកន្លែងអភិរក្សត្រីមេពូជ និងព្រៃលិចទឹក។<br>-ធ្វើ និងដាក់បង្គោលលូស៊ីម៉ង់ និងគល់ឈើក្នុងកន្លែងអភិរក្សត្រីមេពូជ (ជម្រកសប្បនិមិត្ត)។<br>-ធ្វើ និងបោះបង្គោលក្នុង កន្លែងអភិរក្សព្រៃលិចទឹក។ | -នឹងមានស្លាកសញ្ញាកន្លែអភិរក្ស ត្រីមេពូជ និង ព្រៃលិចទឹក។<br>-នឹងមានបង្គោល លូ ស៊ីម៉ងត៍ និងគល់ឈើសម្រាប់ដាក់ក្នុងកន្លែងអភិរក្សត្រីមេពូជ។<br>-នឹងមានបង្គោលសម្រាប់បោះក្នុងកន្លែងអភិរក្សព្រៃលិចទឹក។ | ៣០០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និង គម្រោង SIFAL | ២០១៧ | ២០១៩ | |
| ៣. ផែនការគ្រប់គ្រងផែនការព្រៃលិចទឹក | -ធ្វើថ្នាលផ្សាំកូនដើមរាំង និងកូនដើមផ្ទោល។<br>-រៀបចំកន្លែងដែលត្រូវដាំ កូនដើមរាំង និងដើមផ្ទោល។<br>-ដាំដើមឈើចំនួន ២០០០០ដើម។ | -នឹងបានបណ្ដុះកូនដើមរាំង និងផ្ទោលចំនួន២០០០០ដើម។<br>-នឹងបានដាំកូនដើមរាំង និងផ្ទោលចំនួន ២០០០០ដើមនៅកន្លែងអភិរក្ស។ | ១៤០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និង គម្រោង SIFAL | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | -បង្កើតក្រុមចិញ្ចឹមត្រីអណ្តែង និងត្រីឆ្ពិន។<br>-ដឹកនាំ និងចូលរួមវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីឆ្ពិន និងត្រីអណ្តែង។ | -ក្រុមចិញ្ចឹមត្រីអណ្តែងត្រូវបានបង្កើត និងបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រី។<br>-សហគមន៍នេសាទ នឹងមានចំណេះដឹងអំពីការចិញ្ចឹមត្រីឆ្ពិន និងត្រីអណ្តែង។ | ១៥០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ៥. ផែនការរកចំណូលសហគមន៍ | ដឹកនាំផ្សព្វផ្សាយ និងប្រមូលប្រាក់វិភាគទានប្រចាំឆ្នាំ និងរៀបចំគម្រោងផែនការស្នើសុំថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ។ | -សមាជិកសហគមន៍នេសាទទាំងអស់នឹងបានបង់ប្រាក់វិភាគទានប្រចាំឆ្នាំដោយស្ម័គ្រចិត្ត។<br>-គណៈកម្មការសហគមន៍នេសាទនឹងបានរៀបចំធ្វើគម្រោងផែនការស្នើសុំថវិកាពីគម្រោង ឬអង្គការនានា។ | ៥០០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ៦. ផែនការបង្កើនមុខរបរចិញ្ចឹមជីវិត | -បង្កើតក្រុមចិញ្ចឹមជ្រូកនិងមាន់។<br>-ដឹកនាំ និងចូលរួមវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេស បង្កើនមុខរបរចិញ្ចឹមជីវិតសមស្រប។<br>-បង្កើតក្រុមកែច្នៃត្រី (ត្រីឆ្អើ ប្រហុក) | -ក្រុមបង្កើនមុខរបរចិញ្ចឹមជីវិត នឹងត្រូវបានបង្កើតតាមជំរើសមុខរបរ សមស្រប<br>-សហគមន៍នេសាទនឹងមានចំណេះដឹងអំពីមុខរបរចិញ្ចឹមជីវិតសមស្រប | ៣០០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ៧. ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | -ចូលរួមបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសហគមន៍នេសាទ វិធីសាស្ត្រផ្សព្វផ្សាយ វិធីសាស្ត្រស្វែងថវិកា និងការសរសេរគម្រោងសំណើ | -សហគមន៍នឹងមានចំណេះដឹង និងពង្រឹងសមត្ថភាពបន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាល។ | ៣០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សុំថវិកា ច្បាប់ស្តីពីជលផល ជំនាញក្នុងការសម្របសម្រួល និងការ។<br>-គៀងគរអោយមានការចូលរួមក្នុងសហគមន៍។ | | | SIFAL | | | |
| ៨. ផែនការសាងសង់សហគមន៍នេសាទ | -ទិញឈើ និងសម្ភារៈសម្រាប់ធ្វើស្នាក់ការសហគមន៍នេសាទ។<br>-ដឹកនាំធ្វើស្នាក់ការសហគមន៍នេសាទ។ | -មានស្នាក់ការសហគមន៍នេសាទ។ | ៤០៩៥ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ៩.ចុះល្បាត | -បង្កើតក្រុមល្បាត<br>-រៀបចំផែនការចុះល្បាត<br>-ទិញសម្ភារៈគាំទ្រការចុះល្បាត<br>-ចុះល្បាតជាទៀងទាត់<br>-ចុះល្បាតដោយសហការជាមួយជំនាញជលផល និងអាជ្ញាធរក្នុងករណីបន្ទាន់ | -ក្រុមល្បាតបានបង្កើតដោយមានតំណាងក្រុមយ៉ាងហោចណាស់៥នាក់ក្នុងមួយក្រុម និងមាន៥ក្រុម។<br>-ផែនការចុះល្បាតនិងត្រូវបានរៀបចំដោយគណៈកម្មការសហគមន៍និងតំណាងក្រុមល្បាត។<br>-សម្ភារៈល្បាតនឹងទិញដើម្បីគាំទ្រចុះល្បាត។<br>-សហគមន៍ចុះល្បាតជាទៀងទាត់៤ដងក្នុងមួយខែ។ | ១០០០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និងគម្រោង SIFAL | ២០១៧ | ២០១៩ | |
| ១០.ប្រជុំប្រចាំខែគណៈកម្មការ | -ប្រជុំគណៈកម្មការសហគមន៍នេសាទប្រចាំខែ | -គណៈកម្មការនិងរៀបចំប្រជុំប្រចាំខែរៀងរាល់ខែដើម្បីបង្ហាញពីភាពរីកចម្រើន | ៣៦០ដុល្លា | បដិភាគរបស់សហគមន៍ | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | បញ្ហាប្រឈម ដំណោះស្រាយនិងរៀបចំផែនការសកម្មភាពសម្រាប់ខែបន្ទាប់ | | នេសាទ និង គម្រោង SIFAL | | | |
| ១១.ប្រជុំប្រចាំត្រីមាសជាមួយក្រុមប្រឹក្សាឃុំ | -ប្រជុំគណៈកម្មការសហគមន៍នេសាទប្រចាំត្រីមាស។ | -គណៈកម្មការនឹងរៀបចំកិច្ចប្រជុំប្រចាំត្រីមាសរយៈពេល៣ខែម្តងដើម្បីបូកសរុបលទ្ធផលការងារ និងលើកផែនការត្រីមាសបន្ទាប់។ | ២៤០ដុល្លា | បដិភាគរបស់សហគមន៍នេសាទ និង គម្រោង SIFAL | ២០១៧ | ២០១៩ | |

**តារាងកម្មវិធីការងារ**

| សកម្មភាព | ការបរិច្ឆេទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៧ | | | | | | | ២០១៨ | | | | | | | | | | | | ២០១៩ | | | | | | | | | | | |
| | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១. ផែនការប្រើប្រាស់ ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ២. ការកែលំអរ និងរៀបចំកន្លែងអភិរក្សសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៣ .ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៤. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៥. ផែនការរកចំណូលសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៦. ផែនការបង្កើតមុខរបរចិញ្ចឹមជីវិត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៧. ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | → | | | | | | | | | | | | |
| ៨. ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ | | | | | | | | | | | | | | → | | | | | | | | | | | | | | | | | |
| ៩. ផែនចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ១០.ផែនការ ប្រជុំប្រចាំខែគណៈកម្មការ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ១១. ផែនការប្រជុំប្រចាំត្រីមាសជាមួយក្រុមប្រឹក្សាឃុំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ១២. ផែនការប្រជុំប្រចាំឆ្នាំរបស់សហគមន៍ | | | | | | | → | | | | | | | | | | | | → | | | | | | | | | | | | → |

លេខ:........................
បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ
"ដើម្បីជូនពិនិត្យនិងសម្រួល"
...........ថ្ងៃទី 24 ខែ 07 ឆ្នាំ២០១៧
**នាយផ្នែករដ្ឋបាលជលផលផាត់សណ្ដាយ**

បានឃើញនិងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលផាត់សណ្ដាយ
"ដើម្បីជូនពិនិត្យនិងសម្រួល"
........ថ្ងៃទី 24 ខែ 07 ឆ្នាំ២០១៧
**នាយសង្កាត់រដ្ឋបាលជលផលស្ទោង**

លេខ 3201........
បានឃើញនិងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលស្ទោង
"ដើម្បីជូនពិនិត្យនិងសម្រួល"
........ថ្ងៃទី 24 ខែ 07 ឆ្នាំ២០១៧
**មេឃុំ**

សូមគោរពជូន
លោកមេឃុំចំណោះក្រោម
"ដើម្បីជូនពិនិត្យនិងសម្រួល"
..........ថ្ងៃទី........ខែ......... ឆ្នាំ២០១៧
**ប្រធានគណៈកម្មការសហគមន៍នេសាទ**
**អភិវឌ្ឍន៍ស្ពានក្រុង**

លេខ:...............ជជ
បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី......ខែ.........ឆ្នាំ២០១៧
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

លេខ.............
បានឃើញនិងគោរពជូន
ឯកឧត្ដមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"
............ថ្ងៃទី......ខែ.........ឆ្នាំ២០១៧
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ខេត្តកំពង់ធំ-**

**ធីវ វណ្ណធីរះ**

លេខ :.............
បានឃើញនិងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ខេត្តកំពង់ធំ-
"ដើម្បីជូនពិនិត្យនិងសម្រួល"
..........ថ្ងៃទី......ខែ......ឆ្នាំ២០១៧
**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**